# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ០៤.សរ-៩៣

## <u>សារាចរ</u>

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### <u>សូមផ្ញើជូនចំពោះ</u>

**ឯកឧត្តម ប្រធានតុលាការកំពូល**
**ឯកឧត្តម អគ្គរដ្ឋអាជ្ញាអមតុលាការកំពូល**
**លោក ប្រធានសាលាឧទ្ធរណ៍**
**លោក អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍**
**លោក ប្រធានតុលាការខេត្ត ក្រុង**
**លោក តុលាការយោធា**
**លោក រដ្ឋអាជ្ញាអមតុលាការយោធា**

*<u>សូមជ្រាប។</u>*

***<u>កម្មវត្ថុ:</u>*** ការអនុវត្តច្បាប់ ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដីនៃកម្ពុជា ។

ក្រសួងយុត្តិធម៌ មានកិត្តិយសសូមរំលឹកឡើងវិញ អំពីការអនុវត្តច្បាប់ស្ដីពីការចាត់តាំង និងសម្មភាពរបស់សាលាជម្រះក្ដីនៃកម្ពុជា ឲ្យបានជ្រាបថា ៖

***<u>១-អំពីស្នាក់ការសាលាឧទ្ធរណ៍</u>***

តាមមាត្រា ៣ នៃច្បាប់នេះបានកំណត់ថា សាលាឧទ្ធរណ៍ត្រូវតាំងនៅក្រុងភ្នំពេញ តែមិនទាន់បានកំណត់ទីស្នាក់ការនៅកន្លែងណាមួយក្នុងក្រុងភ្នំពេញនៅឡើយទេ ។ ដើម្បីកំណត់ទីស្នាក់ការនេះក្រសួងយុត្តិធម៌សូមជូនដំណឹងថា ទីស្នាក់ការសាលាឧទ្ធរណ៍ត្រូវបានតាំងនៅអតីតសាលាឧទ្ធរណ៍ស្ថិតនៅមុខព្រះបរមរាជវាំង ។ ដូច្នេះចាប់ពីពេលនេះតទៅក្នុងការទំនាក់ទំនងការងារជាមួយសាលាឧទ្ធរណ៍ឬត្រូវបញ្ជូនរឿងមកសាលាឧទ្ធរណ៍ជំនុំជម្រះ ត្រូវធ្វើទំនាក់ទំនងនិងបញ្ជូនមកសាលាឧទ្ធរណ៍ដែលមានស្នាក់ការដូចបានជម្រាបជូនខាងលើ ។

***<u>២-អំពីការចុះបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ</u>***

មាត្រា ៨.៩ និងមាត្រា ១២ នៃច្បាប់ខាងលើនេះបានកំណត់ថាបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ បើកឲ្យប្ដឹងបានក្នុងកំណត់ ២ ខែ គិតពីថ្ងៃកាត់សេចក្ដីនូវសាលក្រមចំពោះមុខគូក្ដី ឬគិតពីថ្ងៃផុតកំណត់ប្ដឹងទាស់នូវសាលក្រមកំបាំងមុខ ។

បណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ ជួនកាលក្នុងរឿងតែមួយគូក្ដីតែម្ខាងប្ដឹងក៏មាន ឬគូក្ដីទាំងសងខាងប្ដឹងក៏មាន ។ ដូច្នេះក្រឡាបញ្ជីដែលទទួលបន្ទុកចុះបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខត្រូវចុះបណ្ដឹងនោះឲ្យទាំងអស់គ្នាដោយមិនប្រកាន់អ្នកឈ្នះ ឬអ្នកចាញឡើយ និងចុះបញ្ជាក់អំពី បណ្ដឹងឲ្យបានដឹងថា តើមិនសុខចិត្តអំពីសាលក្រមទាំងមូល ឬតែអំពីចំណុចណាមួយនោះទេ ។ ឧទាហរណ៍ មិនសុខចិត្តអំពីសាលក្រមទាំងមូល មិនសុខចិត្តអំពីជម្ងឺចិត្ត ឬមិនសុខចិត្តអំពីសោហ៊ុយ សំណង.......។ល។ ថ្ងៃ ខែ ទទួលចុះបណ្ដឹងឧទ្ធរណ៍ សូមសរសេរជាអក្សរ ។

ក្នុងរឿងរដ្ឋប្បវេណី បើមានបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខនៅពេលទទួលបណ្ដឹងក្រឡាបញ្ជីទទួលបន្ទុកត្រូវណែនាំឲ្យអ្នកប្ដឹងបង់ប្រាក់ប្រដាប់ក្ដីសម្រាប់សាលាឧទ្ធរណ៍ ឬតុលាការកំពូលតាមចំនួនដែលច្បាប់កំណត់ ហើយ

ត្រូវធ្វើកំណត់ហេតុសម្គាល់អំពីការណែនាំនេះដាក់ក្នុងសំណុំរឿងដោយឲ្យអ្នកប្តឹងនិងក្រឡាបញ្ជីចុះហត្ថលេខាលើកំណត់ហេតុនោះផង ។ បើគូក្តីព្រមបង់នៅពេលនោះតែម្តងត្រូវណែនាំឲ្យផ្ញើប្រាក់ប្រដាប់ក្តីនេះតាមអាណត្តិប្រៃសណីយ៍ដាក់ថាចាងហ្វាងសាលាឧទ្ធរណ៍ ឬចាងហ្វាងតុលាការកំពូល ហើយថាជាប្រាក់ប្រដាប់ក្តី ។

ការណែនាំឲ្យបង់ប្រាក់ប្រដាប់ក្តីនេះ មិនមែនមានន័យថាអ្នកប្តឹងគ្មានប្រាក់បង់ប្រដាប់ក្តីមិនឲ្យប្តឹងឧទ្ធរណ៍នោះទេ គឺក្នុងន័យថាអ្នកប្តឹងមានប្រាក់ប្រដាប់ក្តីឬគ្មានប្រាក់បង់ក្តីក្រឡាបញ្ជីត្រូវតែចុះបណ្តឹងឧទ្ធរណ៍ ឬសាទុក្ខឲ្យអ្នកប្តឹងជាដំរាបតាមសូមពររបស់គេ នូវថ្ងៃ ខែ ដែលគេសុំប្តឹងនោះ ហើយត្រូវតែបញ្ជូនសំណុំរឿងមកសាលាឧទ្ធរណ៍ ឬតុលាការកំពូលតាមការកំណត់ ។

ការណែនាំឲ្យបង់ប្រាក់ប្រដាប់ក្តីនេះ គ្រាន់តែជាកិច្ចការមួយសម្រួលដល់ការងារឲ្យបានឆាប់ជៀសវាងការយឺតយូរតែប៉ុណ្ណោះ ។

## ៣-អំពីការបញ្ជូនរឿងមកសាលាឧទ្ធរណ៍ ឬមកតុលាការកំពូល

ក្រឡាបញ្ជីទទួលបន្ទុកចម្លងសាលក្រមសម្រេច ចម្លងកំណត់ហេតុចេញពីសៀវភៅកំណត់ហេតុជំនុំជម្រះ និងចម្លងសេចក្តីនៃបណ្តឹងតវ៉ាដាក់ក្នុងសំណុំរឿង និងធ្វើបញ្ជីរាយនាមលិខិតដែលមាននៅក្នុងសំណុំរឿង រួចហើយបញ្ជូនសំណុំរឿងនោះតាមលិខិតអនុសិទ្ធិមកសាលាឧទ្ធរណ៍ ឬតុលាការកំពូល ។

បើតុលាការដែលមានទីស្នាក់ការនៅជិតក្បែរៗគ្នា អាចនិងបញ្ជូនតាមដីកាបញ្ជូនធម្មតាក៏បានដែរ ។

ការបញ្ជូនសំណុំរឿងពីតុលាការខេត្ត ក្រុង មកសាលាឧទ្ធរណ៍ក្តី ឬពីសាលាឧទ្ធរណ៍មកតុលាការកំពូលក្តី តាមធម្មតាត្រូវតែបញ្ជូនយ៉ាងប្រញាប់ប្រញាល់ឲ្យបានឆាប់បំផុតយ៉ាងយូរក្នុងរយៈ ១ខែ ចាប់ពីថ្ងៃផុតកំណត់ឧទ្ធរណ៍ ឬប្តឹងសាទុក្ខ ។

សូមតុលាការខេត្ត ក្រុង តុលាការយោធា សាលាឧទ្ធរណ៍និងតុលាការកំពូលអនុវត្តតាមការណ៍ណែនាំនេះឲ្យបានហ្មត់ចត់ ហើយបើមានចំណុចណាយល់មិនច្បាស់ សូមសួរមកក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌នឹងឆ្លើយបំភ្លឺតាមសំណូមពរនោះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៣

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-សភាជម្មនុញ្ញ
-ក្រសួងហិរញ្ញវត្ថុ
-អភិបាលខេត្ត ក្រុង
-ដើម្បីជ្រាបជាព័ត៌មាន